**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**

លេខ : ១៧២៣/២០ អ គ រ

ថ្ងៃអង្គារ ៩កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០

**សេចក្តីណែនាំបន្ថែម**

**ស្តីពី**

**នីតិវិធីនៃកិច្ចដំណើរការស្នើសុំលិខិតអនុញ្ញាតគយ តាមប្រព័ន្ធបញ្ជរតែមួយជាតិ**

អនុលោមតាមបញ្ញត្តិអនុក្រឹត្យលេខ ១៧អនក្រ.បក ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យប្រើប្រាស់បញ្ជីមុខទំនិញហាមឃាត់និងទំនិញជាប់កម្រិតកំណត់, ប្រកាសលេខ ៥៧៥ សហវ.ប្រក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៩ របស់គណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ ស្តីពីការដាក់ឱ្យអនុវត្តជំហានដំបូងប្រព័ន្ធបញ្ជរតែមួយជាតិ, សេចក្តីណែនាំលេខ ១៨៨២/១៩.អគរ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ និងសេចក្តីណែនាំបន្ថែមលេខ ២៧០០/១៩.អគរ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ស្តីពីកិច្ចដំណើរការលិខិតអនុញ្ញាតគយតាមប្រព័ន្ធបញ្ជរតែមួយជាតិ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា សូមកំណត់បន្ថែមនូវនីតិវិធី នៃកិច្ចដំណើរការលិខិតអនុញ្ញាតគយសម្រាប់មុខទំនិញដែលស្ថិតក្នុងបញ្ជីទំនិញហាមឃាត់និងទំនិញជាប់កម្រិតដូចខាងក្រោម÷

**I. ចំពោះអាជ្ញាប័ណ្ណ វិញ្ញាបនបត្រ លិខិតអនុញ្ញាត ឬបញ្ជីមេមុខទំនិញដែលចេញដោយប្រព័ន្ធបញ្ជរតែមួយជាតិ**

១. ម្ចាស់ទំនិញ ឬតំណាងដែលទទួលបានការអនុញ្ញាតក្នុងការបំពេញបែបបទស្នើសុំលិខិតអនុញ្ញាតគយ មានភារកិច្ចទទួលខុសត្រូវដូចខាងក្រោម÷

- ត្រូវអនុវត្តការស្នើសុំលិខិតអនុញ្ញាតគយ តាមប្រព័ន្ធបញ្ជរតែមួយជាតិ ស្របតាមនីតិវិធីនៃកិច្ចដំណើរការលិខិតអនុញ្ញាតគយ ដូចមានចែងក្នុងសេចក្តីណែនាំលេខ ១៨៨២/១៩ អគរ និងសេចក្តីណែនាំបន្ថែមលេខ ២៧០០/១៩ អគរ ដូចយោងខាងលើ
- ត្រូវបំពេញក្នុងប្រអប់លេខយោងនៃអាជ្ញាប័ណ្ណ/បញ្ជីមេ នៃប្រព័ន្ធបញ្ជរតែមួយជាតិ នូវលេខយោងនៃអាជ្ញាប័ណ្ណ វិញ្ញាបនបត្រ លិខិតអនុញ្ញាត ឬបញ្ជីមេមុខទំនិញ ដែលបានចេញដោយក្រសួង-ស្ថាប័នពាក់ព័ន្ធឱ្យបានគ្រប់គ្រាន់ និងត្រឹមត្រូវ។

២. នាយកដ្ឋានទទួលបន្ទុកចេញលិខិតអនុញ្ញាតគយ ត្រូវចាត់ចែងមន្ត្រីគយនិងរដ្ឋាករមានសមត្ថកិច្ចក្នុងការទទួលបន្ទុកគ្រប់គ្រងនូវអាជ្ញាប័ណ្ណ វិញ្ញាបនបត្រ លិខិតអនុញ្ញាត ឬបញ្ជីមេមុខទំនិញដែលចេញដោយប្រព័ន្ធបញ្ជរតែមួយជាតិ។ មន្ត្រីគយនិងរដ្ឋាករមានសមត្ថកិច្ចទទួលបន្ទុកតាមដំណាក់កាលនីមួយៗ មានភារកិច្ចទទួលខុសត្រូវក្នុងការគ្រប់គ្រង និងអនុវត្តនីតិវិធីនៃកិច្ចដំណើរការលិខិតអនុញ្ញាតគយតាមប្រព័ន្ធបញ្ជរតែមួយជាតិ ប្រកបដោយភាពទទួលខុសត្រូវខ្ពស់។



អាសយដ្ឋាន: លេខ ៦-៨ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ កម្ពុជា
ទូរសព្ទ / ទូរសារ: (៨៥៥-២៣) ២១៤ ០៦៥ / ៧២៥ ១៨៧ / ២១២ ៤៥៧ / E-mail: info-pru@customs.gov.kh

**II. ចំពោះអាជ្ញាប័ណ្ណ វិញ្ញាបនបត្រ ឬលិខិតអនុញ្ញាត ដែលពុំប្រើប្រាស់ប្រព័ន្ធបញ្ជរតែមួយជាតិ**

ម្ចាស់ទំនិញ ឬតំណាងដែលទទួលបានការអនុញ្ញាតក្នុងការបំពេញបែបបទស្នើសុំលិខិតអនុញ្ញាតគយ ត្រូវអនុវត្តតាមលំហូរនីតិវិធីដែលបានកំណត់ដោយ អគរ កន្លងមក ជាធរមានដដែល។

ទទួលបានសេចក្តីណែនាំនេះ សូមលោក លោកស្រីអគ្គនាយករង ប្រធានលេខាធិការដ្ឋាន ប្រធាននាយកដ្ឋាន ប្រធានអង្គភាពគយនិងរដ្ឋាករ និងភាគីពាក់ព័ន្ធទាំងអស់ ត្រូវអនុវត្តតាមខ្លឹមសារនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា**

**ចម្លងជូន÷**

- ខុទ្ទកាល័យឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ “ដើម្បីជូនជ្រាប”
- គ្រប់អង្គភាពគយនិងរដ្ឋាករ “ដើម្បីអនុវត្ត”
- សភាពាណិជ្ជកម្មកម្ពុជា “ដើម្បីសហការផ្សព្វផ្សាយ”
- ឯកសារ - កាលប្បវត្តិ

**បណ្ឌិត គុណ-ញឹម**